**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

**អគ្គាធិការដ្ឋាន**

ថ្ងៃ ខែ មគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦

លេខៈ __________ អ.គ.ជ/ក.អ.ជ

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០២២

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ ៖** របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ របស់អគ្គាធិការដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ។

## I. សេចក្តីផ្តើម

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងអភិវឌ្ឍន៍ជនបទ លើបេសកកម្មធ្វើអធិការកិច្ចតាមបណ្តានាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង និងអធិការកិច្ចផ្អែកលើករណីសង្ស័យ ឬករណីបណ្តឹងតវ៉ាដាក់ស្តែង។

អគ្គាធិការដ្ឋាន មានភារកិច្ចតាមដាន ត្រួតពិនិត្យ ស្រាវជ្រាវលើសកម្មភាពការងារគ្រប់អង្គភាពក្រោមឱវាទក្រសួង និងគម្រោងកម្មវិធីនានាដែលមានកិច្ចសហប្រតិបត្តិការក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ធ្វើការសន្និដ្ឋាន និងវាយតម្លៃចំពោះការងាររបស់អង្គភាពទាំងនោះដែលបានអនុវត្តកន្លងមកក្នុងគោលបំណងដើម្បីពង្រឹងឱ្យមានគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពការងារ នៅក្នុងការងារដឹកនាំ និងគ្រប់គ្រង មានភារកិច្ចសម្របសម្រួល និងដោះស្រាយ វិវាទ បណ្តឹង បញ្ហាមិនប្រក្រតីផ្សេងៗដែលកើតមានឡើងជាយថាហេតុ នៅតាមអង្គភាពក្រោមឱវាទក្រសួង។

## II. លទ្ធផលសម្រេចបាន

### ១-ការងារគ្រប់គ្រងបុគ្គលិក

អគ្គាធិការដ្ឋាន មានមន្ត្រីរាជការសរុបចំនួន ៣៧រូប (ស្ត្រីចំនួន ១០រូប) និងមន្ត្រីជាប់កិច្ចសន្យាចំនួន ០១រូប ក្នុងនោះរួមមាន៖

| ល.រ | អង្គភាព | ចំនួនមន្ត្រីរាជការ | | | មុខងារ | | | |
|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | អគ្គាធិការ | អគ្គាធិការរង | អធិការ | អធិការរង |
| ១ | ថ្នាក់ដឹកនាំ | ១៥ | ៣ | ១៨ | ១ | ៧ | ២ | ៨ |
| ល.រ | ថ្នាក់ការិយាល័យ | ប្រុស | ស្រី | សរុប | ប្រធានការិ. | អនុ.ការិ. | មន្ត្រី | ផ្សេងៗ |
| ១ | ការិ. កិច្ចការទូទៅ | ២ | ៣ | ៥ | ១ | ២ | ២ | |
| ២ | ការិ. អធិការកិច្ច បច្ចេកទេស | ៦ | ១ | ៧ | ១ | ២ | ៤ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | ការិ.អធិការកិច្ច រដ្ឋបាល និងហិរញ្ញវត្ថុ | ៤ | ៣ | ៧ | ១ | ២ | ២ | |
| ៤ | មន្ត្រីជាប់កិច្ចសន្យា | ១ | ០ | ១ | | | | |
| | សរុប | ២៨ | ១០ | ៣៨ | | | | |

**២-ការងារគ្រប់គ្រងរដ្ឋបាល**

**ក-លិខិតចូល៖**

បានទទួលលិខិតមកពីក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ចំនួន ២៣០ ច្បាប់រួមមាន៖

- លិខិតមកពីក្រសួង ស្ថាប័ននានា ចំនួន ៦០ ច្បាប់
- អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ១៧០ ច្បាប់

**ខ-លិខិតចេញ៖**

បានចុះលេខលិខិតចេញសរុប ចំនួន ៩៧ ច្បាប់រួមមាន៖

- លិខិតចេញទូទៅ ចំនួន ៧៥ ច្បាប់
- លិខិតចេញពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ចំនួន ១១ ច្បាប់
- លិខិតបញ្ជាបេសកកម្ម ចំនួន ១១ ច្បាប់

**៣-ការងារអធិការកិច្ចតាមបណ្តាមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត**

ចុះធ្វើអធិការកិច្ចនៅតាមមន្ទីរអភិវឌ្ឍន៍ជនបទចំនួន ១៦ រាជធានី ខេត្ត រួមមាន៖ ព្រៃវែង ខេស្វាយរៀង កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ រតនគីរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង សៀមរាប បន្ទាយមានជ័យ កំពង់ធំ និងខេត្តកំពង់ចាម

**៤-ការងារទំនាក់ទំនង កិច្ចប្រជុំ និងសិក្ខាសាលា**

ក្នុងឆ្នាំ២០២២នេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអគ្គាធិការដ្ឋានបានចូលរួមសកម្មភាពការងារផ្សេងៗដូចខាងក្រោម៖

- ដឹកនាំកិច្ចប្រជុំបូកសរុបរបាយការណ៍ការងារប្រចាំខែរបស់អគ្គាធិការដ្ឋាន បានចំនួន ១១លើក
- ចូលរួមប្រជុំចចារថ្លៃ លើគម្រោងការងារស្តាបនាផ្លូវ លូ និងស្ពានចំនួន ២២លើក នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមចុះត្រួតពិនិត្យ និងវាយតម្លៃប្រគល់-ទទួល លើការងារជួសជុល ស្តាបនាផ្លូវ និងលូ បានចំនួន ១៦លើក
- ចូលរួមប្រគល់-ទទួល ការទិញសម្ភារ ប្រើប្រាស់ក្នុងឆ្នាំ ២០២២ ជូនបណ្តានាយកដ្ឋាននៃក្រសួងអភិវឌ្ឍន៍បទ បានចំនួន ០២លើក
- ចូលរួមសិក្ខាសាលា បើកវគ្គបណ្តុះបណ្តាលស្តីពីផែនការនិរន្តរភាពការងារ តាមរយៈប្រព័ន្ធអនឡាញ ZOOM
- ចូលរួមបើក-បិទ សិក្ខាសាលាបូកសរុបលទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ ២០២១ និងលើកទិសដៅការងារបន្ត លើវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ
- ចូលរួមពិធីប្រគល់ជ័យលាភីដល់សិស្សប្រលងជាប់និទ្ទេស A និងសម្ពោធសួនច្បារគណបក្សខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព **សម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**

**ព្រះបរមរាជវាំង** អមដំណើរដោយ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** ឯកឧត្តមទេសរដ្ឋមន្ត្រី **គុយ សុផល** ឯកឧត្តម **ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងអាជ្ញាធរមូលដ្ឋាន

– ចូលរួមប្រជុំ ស្តីពីការចុះប្រមូលព័ត៌មាន ដើម្បីរៀបចំផែនការសវនកម្ម និងធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ និងធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ក្រោមប្រធានបទ "លើកកម្ពស់អនាម័យនៅជនបទ" របស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការិយបរិច្ឆេទ២០២១ ក្រោមអធិបតីភាព **ឯកឧត្តម ប៊ុន ច័ន្ទវណ្ណៈ** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង

– ចូលរួមជាគណៈអធិបតីក្នុងពិធីបើក-បិទ អង្គវិបស្សនារបស់ក្រុមការងារផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ (WATSAN RETREAT) នៅរមណីយដ្ឋាន ម៉េម៉ូរីយ៉ា ផាឡេស ខេត្តប៉ៃលិន

– ចូលរួមជាគណៈអធិបតីក្នុងពិធីបិទសន្និបាត បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** នៅសាលប្រជុំសាលាខេត្តកំពង់ឆ្នាំង

– ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារប្រចាំឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅជាន់ទី៨ ទីស្តីការក្រសួង

– ចូលរួមសិក្ខាសាលាតាមដានវគ្គបណ្តុះបណ្តាលស្តីពី ផែនការនិរន្តរភាពការងារ (Business Continuity Plan E-Course Follow Up workshop) តាមរយៈប្រព័ន្ធអនឡាញ Zoom

– ជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រី របស់អគ្គាធិការដ្ឋាន ដើម្បីចូលរួមអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២២

– ចូលរួមពិធីប្រកាសទទួលស្គាល់ផ្លូវការខេត្តស្វាយរៀង កំពង់ឆ្នាំ និងខេត្តព្រៃវែង ដែលទទួលបានជោគជ័យក្នុងការបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** នៅខេត្តស្វាយរៀង

– អមដំណើរ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ចុះត្រួតពិនិត្យការងារស្ថាបនាផ្លូវរបស់គម្រោងកែលម្អផ្លូវជនបទជំហានទី៣ នៅខេត្តស្វាយរៀង

– ចូលរួមបេសកកម្ម ដែលដឹកនាំដោយ **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងគណៈប្រតិភូអន្តរក្រសួងចុះត្រួតពិនិត្យទីតាំងដីស្នើសុំកែសម្រួលព្រំប្រទល់តំបន់២ និងតំបន់៣នៃតំបន់បឹងទន្លេសាបក្នុងឃុំសំពោងសែន ឃុំផ្លូវទូក និងឃុំប្រឡាយមាស ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

– ចូលរួមកិច្ចប្រជុំការងារ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** នៅសាលប្រជុំជាន់ទី៨ ទីស្តីការក្រសួង

– ចូលរួមកិច្ចប្រជុំ ស្តីពីការពង្រឹងការគ្រប់គ្រងការងារបុគ្គលិក ក្រោមអធិបតីភាព **ឯកឧត្តម សាន វិសាល** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធ ZOOM

– ចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣-២០២៥ និងថវិកាសមិទ្ធកម្ម ឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារផ្ទេរសុខា ខេត្តព្រះសីហនុ

– ចូលរួមជាគណៈអធិបតីក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការចុះអធិការកិច្ចហិរញ្ញវត្ថុ ផ្អែកតាមអនុលោមភាពលើការគ្រប់គ្រងអនុវត្តចំណូល-ចំណាយថវិកាជាតិ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០២១ និងឆ្នាំពាក់ព័ន្ធ នៅក្រសួងអភិវឌ្ឍន៍ជនបទ និងបណ្តាអង្គភាពថវិកាក្រោមចំណុះ ក្រោមអធិបតីភាព **លោកជំទាវ ហូ សុវណ្ណិកា** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី៧ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

– ចូលរួមសិក្ខាសាលាស្តីពី រដ្ឋាភិបាលឌីជីថល (Virtual Symposium on Digital Government) ក្រោមអធិបតីភាព **ឯកឧត្តម ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ តាមប្រព័ន្ធអនឡាញ ZOOM

– ចូលរួមកិច្ចប្រជុំពិភាក្សា កម្រិតបច្ចេកទេសលើគម្រោងផែនការចំណូល-ចំណាយថវិកាឆ្នាំ ២០២៣ ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង

– ចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយលទ្ធផល នៃការអនុវត្តថវិកាកម្មវិធី ក្រោមអធិបតីភាព **ឯកឧត្តម ហួត សារឹម** អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារ ខេមរាអង្គរ ខេត្តសៀមរាប

– ចូលរួមជាគណៈប្រតិភូក្នុងពិធីព្រលែងត្រីអបអរសាទរទិវាមច្ឆាជាតិ ១ កក្កដា នៅអាងទឹកឈ្វាំង ស្ថិតនៅភូមិព្រៃខ្មែរ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង និង ជួបសំណេះសំណាលពិភាក្សាការងារជាមួយមេឃុំទាំង១៤ ក្នុងស្រុករលាប្អៀរ

– ចូលរួមជាគណៈប្រតិភូ ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវក្រាលកៅស៊ូ ចំនួន ០២លើក ស្ថិតនៅខេត្តកំពង់ឆ្នាំង និងខេត្តព្រៃវែង

– ចូលរួមកិច្ចប្រជុំពិភាក្សាលើគម្រោងផែនការថវិកាក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ ២០២៣ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– ចូលរួមកិច្ចប្រជុំពិភាក្សាអំពីធាតុចូល (Input) ដើម្បីរៀបចំផែនការមេស្តីពីការងារអភិវឌ្ឍន៍អាស៊ានឆ្នាំ ២០២២-២០២៦

– ចាត់បញ្ជូនមន្ត្រីរាជការចំនួន ០២រូប ចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច នៅវិទ្យាស្ថានជាតិអធិការកិច្ច ទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

– ចូលរួមជាគណៈប្រតិភូក្នុងពិធីជួបសំណេះសំណាល និងសួរសុខទុក្ខនាយទាហាន នាយទាហានរង ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ នៅកងពលតូចថ្មើរជើងលេខ ៥២

– ចូលរួមវគ្គបណ្តុះបណ្តាលនៃកម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំនយោបាយ "វគ្គគ្រាប់ពូជល្អ" ចាប់ពីថ្ងៃទី១២-១៦ ខែកញ្ញា ឆ្នាំ២០២២ នៅអគារខេមរានី រាជធានីភ្នំពេញ

– ចូលរួមជាគណៈអធិបតី ក្នុងទិវាអន្តរជាតិជនជាតិដើមភាគតិចពិភពលោកលើកទី២៨ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** នៅសាលមហោស្រព ខេត្តក្រចេះ

– ចូលរួមប្រជុំពិភាក្សា ការងាររៀបចំសេចក្តីព្រាងវិសោធនកម្មលើអនុក្រឹត្យស្តីពីការរៀបចំប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលដឹកនាំដោយ **ឯកឧត្តម ភួង សោភា រដ្ឋលេខាធិការ** នៅសាលប្រជុំជានទី១ ទីស្តីការក្រសួង

– ចូលរួមបើកឯកសារដេញថ្លៃ ស្តីពីការថែទាំជួសជុលអគារទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ សម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០២២ ក្រោមអធិបតីភាព **ឯកឧត្តម សាន វិសាល រដ្ឋលេខាធិការ** នៅសាលប្រជុំជាន់ទី៣ ទីស្តីការក្រសួង

– ចូលរួមជាគណៈអធិបតី ក្នុងពិធីបើកសិក្ខាសាលា ស្តីពីការចាប់ផ្តើមគម្រោងកម្មវិធីអភិវឌ្ឍន៍ និងធ្វើឱ្យប្រសើរឡើងលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយនិរន្តរភាព ជំហានទី ៤ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ

– ចាត់មន្ត្រីរាជការចូលរួមក្នុងពិធីប្រទានភ្លើងជ័យ និងពិធីពន្លត់ភ្លើងជ័យ នៅវិមានឯករាជ្យ

– ចាត់មន្ត្រីរាជការចូលរួមទទួលគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយ**ព្រះចៅស៊ុលតង់** HAJI HASSANAL BOLKIAH ព្រះមហាក្សត្រ និងជាព្រះប្រមុខរដ្ឋ នៃប្រទេសព្រុយណេ នៅមុខព្រះបរមរាជវាំង

– ចូលរួមប្រជុំពិនិត្យសេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យលេខ ៧៨ និង ៥១ ស្តីពីដំណើរការ និងប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព **ឯកឧត្តម ភួង សោភា រដ្ឋលេខាធិការ** នៅទីស្តីការក្រសួង

– ចូលរួមអមដំណើរ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវជនបទក្រាលកៅស៊ូ និងផ្លូវបេតុង នៅភូមិសាវ៉ាយអណ្តែត ឃុំជ្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

– ចូលរួមអមដំណើរ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** អញ្ជើញជាអធិបតីក្នុងពិធីបើកការដ្ឋានស្តារឡើងវិញផ្លូវជនបទក្រាលបេតុង ០១ខ្សែ នៅភូមិក្តុលលើ ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

– ចាត់មន្ត្រីរាជការចូលរួមក្នុងពិធីបើក និងបិទ កីឡាជាតិលើកទី៣ ឆ្នាំ២០២២ ក្រោមអធិបតីភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡាដ្ឋានជាតិមរតកតេជោ។

## II. បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលដែលសម្រេចបានខាងលើ ក៏អង្គភាពអគ្គាធិការដ្ឋាននៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖

– សមត្ថភាពជំនាញរបស់មន្ត្រីនៅមានកម្រិត
– ខ្វះខាតលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ និងការងារអធិការកិច្ច
– ខ្វះមធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យាសមស្របសម្រាប់ចុះបេសកកម្ម។

## III. ទិសដៅការងារបន្ត

– បន្តចុះធ្វើអធិការកិច្ចជាប្រចាំទៅលើអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ

– បន្តចុះពិនិត្យ និងស្រាវជ្រាវ រាល់បណ្តឹងតវ៉ា បណ្តឹងបរិហាររបស់អង្គភាព មន្ត្រីរាជការ ដើម្បីសិក្សាស្រាវជ្រាវ ផ្តល់យោបល់ ឬធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ដើម្បីសុំវិធានការដោះស្រាយ ឬកែលម្អ។

– ប្រតិបត្តិការកិច្ចដែល **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ប្រគល់ជូន។

## IV. **សេចក្តីសន្និដ្ឋាន**

តាមរយៈការអនុវត្តផែនការសកម្មភាពក្នុង ឆ្នាំ២០២២ កន្លងមក ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គាធិការដ្ឋាន បានខិតខំយកចិត្តទុកដាក់បំពេញភារកិច្ចប្រចាំថ្ងៃតាមតួនាទីយ៉ាងសកម្ម ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពការងារ និងចូលរួមចំណែកទប់ស្កាត់ ក៏ដូចជាកាត់បន្ថយរាល់បាតុភាពមិនប្រក្រតីផ្សេងៗដែលអាចកើតមានឡើង ដើម្បីទទួលបាននូវអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងដឹកនាំផ្ទៃក្នុងនៅតាមបណ្តាមន្ទីរ អង្គភាពក្រោមឱវាទក្រសួង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើសូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**អគ្គាធិការ**

បានឃើញ និងសូមគោរពជូន

**លោកជំទាវរដ្ឋលេខាធិការ ទទួលបន្ទុក**

មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០២២

**អនុរដ្ឋលេខាធិការ**

**បានឃើញ និងសូមគោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០២២

**រដ្ឋលេខាធិការ**

<u>ចម្លងជូន៖</u>

- លោកជំទាវរដ្ឋលេខាធិការទទួលបន្ទុក
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក
- នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
  "គោរពជូនជ្រាប"
- ឯកសារ កាលប្បវត្តិ